www.clbs.asia

ឆ្នាំទី១៥ លេខ ០៩ សប្តាហ៍ទី ១ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ រាជកិច្ច ទំព័រ ១១០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០១...អ.ស.ស.ស

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់
- បានឃើញសេចក្តីសម្រេចលេខ៥១សសរ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ (គ.ម.ច.) ដូចខាងក្រោម៖

១-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ៣-ឯកឧត្តម | **ឃី យ៉ុន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោកជំទាវ | **ស៊ុំ ដេហ្វីន** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **នុត សាអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦-ឯកឧត្តម | **កែវ រ៉េមី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-ឯកឧត្តម | **ជូ គឹមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨-ឯកឧត្តម | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩-ឯកឧត្តម | **ហេង តៃគ្រី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០-ឯកឧត្តម | **ឆ្លោក ផន** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ១១-ឯកឧត្តម | **គ្រី មេង** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២-ឯកឧត្តម | **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន-និងកីឡា | សមាជិក |
| ១៣-ឯកឧត្តម | **សន ស៊ីថន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤-ឯកឧត្តម | **ម៉ៅ អាយុទ្ធ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៥-ឯកឧត្តម | **រស់ សុផាន់** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៦-លោកជំទាវ | **ម៉ែន នារីសោភ័គ** | អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា | សមាជិកា |
| ១៧-ឯកឧត្តម | **ទេស ហេង** | អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| ១៨-ឯកឧត្តម | **លឹម ណាយ** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានលេខាធិការដ្ឋាននៃ គ.ម.ច. | លេខាធិការ។ |

**ប្រការ២.-**

សេចក្តីសម្រេចលេខ៥១សសរ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិមនុស្សចាស់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ[illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ